**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**

លេខ : ៣៤០៤ សជណ

ថ្ងៃសុក្រ ១០កើត ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២០

# ជម្រាបជូន
## ឯកឧត្តម លោកជំទាវអភិបាល នៃគណៈអភិបាលរាជធានី ខេត្ត

**កម្មវត្ថុ** ៖ ស្តីពីការដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវកម្មវិធីព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រង និងផ្តល់សេវានៅក្នុងអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត។

**យោង** ៖
- សេចក្តីសម្រេចលេខ០០០៣ សសរ/អរប ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០ របស់អគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ
- លិខិតលេខ០១៩៥ សជណ/អរប ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២០ របស់អគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តម លោកជំទាវអភិបាល នៃគណៈអភិបាលរាជធានី ខេត្ត** មេត្តាជ្រាបថា ដើម្បីធ្វើទំនើបកម្មការផ្តល់សេវារដ្ឋបាលនៅតាមអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្តស្របតាមគោលនយោបាយអភិវឌ្ឍន៍វិស័យទូរគមនាគមន៍-បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ក្រសួងមហាផ្ទៃបានរៀបចំកម្មវិធីព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រង និងផ្តល់សេវានៅក្នុងអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត ដែលកម្មវិធីនេះមានអត្ថប្រយោជន៍សម្រាប់កត់ត្រាទិន្នន័យរួមមានចំនួនសេវា ចំណូលសេវា និងការតាមដានអំពីដំណើរការផ្តល់សេវារបស់អង្គភាពច្រកចេញចូលតែមួយ។ ទន្ទឹមនេះ ប្រជាពលរដ្ឋក៏អាចពិនិត្យមើលអំពីរយៈពេលនៃការពិនិត្យសម្រេចលើសំណើសុំសេវារបស់ខ្លួនតាមដំណាក់កាលនីមួយៗ តាមប្រព័ន្ធទូរស័ព្ទដៃផងដែរ។ បច្ចុប្បន្ន កម្មវិធីព័ត៌មានវិទ្យានេះត្រូវបានអភិវឌ្ឍចប់សព្វគ្រប់ និងត្រូវបានយកមកបណ្តុះបណ្តាលដល់ថ្នាក់ដឹកនាំអង្គភាព និងអ្នកពាក់ព័ន្ធ អំពីរបៀបនៃការប្រើប្រាស់កម្មវិធីព័ត៌មានវិទ្យារួចរាល់ហើយ។

ដើម្បីធានាប្រសិទ្ធភាពក្នុងការប្រើប្រាស់ និងការដាក់ឱ្យដំណើរការកម្មវិធីព័ត៌មានវិទ្យាខាងលើនៅតាមអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត ក្រសួងមហាផ្ទៃ សូមធ្វើការណែនាំដូចខាងក្រោម៖

១- រដ្ឋបាលរាជធានី ខេត្តត្រូវដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវកម្មវិធីព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រង និងផ្តល់សេវានៅក្នុងអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត **ចាប់ពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០ នេះតទៅ**

២- រដ្ឋបាលរាជធានី ខេត្ត ត្រូវផ្តល់ការគាំទ្រលើការបំពាក់សម្ភារ និងបរិក្ខានានា៖
- រៀបចំបណ្តាញNetwork និងភ្ជាប់ប្រព័ន្ធអ៊ីនធឺណែតដែលមានល្បឿនលឿន និងមិនមានភាពរអាក់រអួលចូលអង្គភាពច្រកចេញចូលតែមួយដោយផ្ទាល់
- រៀបចំឱ្យមានកុំព្យូទ័រម្នាក់មួយគ្រឿងសម្រាប់បុគ្គលិកផ្នែកជួរមុខ ក្នុងនោះកុំព្យូទ័ររបស់បុគ្គលិកទទួល-ប្រគល់ឯកសារ និងបុគ្គលិកបេឡា **ត្រូវមានអេក្រង់ចំនួនពីរ** (អេក្រង់មួយសម្រាប់បុគ្គលិកទទួលបន្ទុកធ្វើការបញ្ចូលទិន្នន័យ ហើយអេក្រង់មួយទៀតសម្រាប់ប្រជាពលរដ្ឋពិនិត្យ និងផ្ទៀងផ្ទាត់ទិន្នន័យ)

➢ រៀបចំឱ្យមានកុំព្យូទ័រយ៉ាងតិចចំនួនមួយគ្រឿង សម្រាប់បុគ្គលិកផ្នែកជួរក្រោយតាមវិស័យជំនាញនីមួយៗ។

៣- អភិបាលរាជធានី ខេត្តត្រូវរៀបចំកិច្ចប្រជុំផ្សព្វផ្សាយអំពីការដាក់ឱ្យប្រើប្រាស់ជាផ្លូវការកម្មវិធីព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រង និងផ្តល់សេវានៅក្នុងអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្តដល់មន្ទីរ អង្គភាពជំនាញ និងអ្នកពាក់ព័ន្ធ ដើម្បីចូលរួមគាំទ្រ និងប្រើប្រាស់កម្មវិធីព័ត៌មានវិទ្យានេះ។

អាស្រ័យហេតុនេះ សូមឯកឧត្តម លោកជំទាវ ជ្រាប និងចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាព។ សូមឯកឧត្តម លោកជំទាវ ទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្ដេចក្រឡាហោម ស ខេង**